ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៧៧១ ព.ណ. [illegible]

# សេចក្ដីណែនាំ
## ស្ដីពីយន្តការ និងនីតិវិធីត្រួតពិនិត្យទំនិញ និងការគ្រប់គ្រងសកម្មភាពអាជីវកម្ម លោហធាតុ-ត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ និងវត្ថុអនុស្សាវរីយ៍

ដើម្បីអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្ដីពីការផ្ដល់សេវាសាធារណៈប្រកបដោយគុណភាព តម្លាភាព ប្រសិទ្ធិភាព និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ធុរជន និងអ្នកប្រើប្រាស់ ជាពិសេសដើម្បីលើកកម្ពស់ការទទួលខុសត្រូវរបស់ម្ចាស់អាជីវកម្ម និងការពារផលប្រយោជន៍ដល់អតិថិជនជាតិ និងអន្តរជាតិក្នុងការលើកស្ទួយកិត្តិយសរបស់ជាតិ ព្រមទាំងដើម្បីទប់ស្កាត់ការលក់លោហធាតុ-ត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ និងវត្ថុអនុស្សាវរីយ៍ក្លែងបន្លំ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងពាណិជ្ជកម្ម សូមធ្វើការណែនាំដូចខាងក្រោម៖

១. អាជីវករ ឬពាណិជ្ជករទាំងឡាយ ត្រូវប្រកាន់ខ្ជាប់នូវភាពសុចរិតក្នុងការធ្វើសកម្មភាពអាជីវកម្ម លក់ដូរ ចែកចាយ និងផ្សព្វផ្សាយពាណិជ្ជកម្ម លោហធាតុ-ត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ និងវត្ថុអនុស្សាវរីយ៍ និងត្រូវផ្ដល់ព័ត៌មានពិតប្រាកដ ច្បាស់លាស់ពាក់ព័ន្ធនឹងទំនិញរបស់ខ្លួនជូនអ្នកប្រើប្រាស់រួមទាំងចេញវិក័យបត្រតាមទម្រង់ប្រើប្រាស់ផ្លូវការ និងមានខ្លឹមសារជាក់លាក់។

២. អ្នកប្រើប្រាស់ត្រូវមានភាពសុចរិតចំពោះការទិញទំនិញ ហើយមុននឹងទិញលោហធាតុ-ត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ និងវត្ថុអនុស្សាវរីយ៍ត្រូវពិនិត្យអោយបានច្បាស់លាស់ និងស្នើសុំវិក័យបត្រទិញ-លក់ពីអាជីវករ។

៣. រាល់អាជីវករ ពាណិជ្ជករដែលប្រកបអាជីវកម្មលោហធាតុ-ត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ ត្រូវបិទស្លាកថ្លៃលើគ្រឿងអលង្ការត្បូងថ្មមានតម្លៃ និងវត្ថុអនុស្សាវរីយ៍។

៤. ការងារត្រួតពិនិត្យ និងបង្ក្រាបការក្លែងបន្លំ៖
- អគ្គនាយកដ្ឋានកាំកុងត្រូល ត្រូវចាត់មន្ត្រីជំនាញចុះត្រួតពិនិត្យការដាក់តាំងលក់ ការចែកចាយលោហធាតុ-ត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ និងវត្ថុអនុស្សាវរីយ៍នៅតាមទីផ្សារ គ្រឹះស្ថានអាជីវកម្ម និងកន្លែងលក់ដូរ ដោយសហការជាមួយមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត។
- អគ្គនាយកដ្ឋានកាំកុងត្រូល ត្រូវរៀបចំក្រុមមន្ត្រីជំនាញ តាមដាន ឃ្លាំពិនិត្យចំពោះបណ្ដាញផ្សព្វផ្សាយនានា ដែលផ្សាយពាណិជ្ជកម្មឃោសនាផលិតផលទំនិញជាលោហធាតុ-ត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ និងវត្ថុអនុស្សាវរីយ៍ ដើម្បីទប់ស្កាត់ និងបង្ក្រាបក្នុងករណីដែលមានការក្លែងបន្លំ។



ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ(៨៥៥)-២៣ ៨៦៦ ៤៦៩
Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA
Phone/Facsimile: (855)-23 866 469

- អគ្គនាយកដ្ឋានកាំកុងត្រូល ត្រូវរៀបចំយន្តការទទួលដោះស្រាយបាតុភាព ឬបញ្ហាផ្សេងៗពីអ្នកប្រើប្រាស់ តាមរយៈការបង្កើតប្រព័ន្ធទំនាក់ទំនង និងប្រអប់ទទួលពត៌មានពាក់ព័ន្ធនឹងការប្តឹងតវ៉ាពីអ្នកប្រើប្រាស់។

៥. អាជីវករ ពាណិជ្ជករទាំងឡាយណាដែលផ្គត់ផ្គង់ ចែកចាយ លក់ដូរ ឬផ្សាយពាណិជ្ជកម្ម លោហធាតុ-ត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ និងវត្ថុអនុស្សាវរីយ៍ដោយក្លែងបន្លំជូនអ្នកប្រើប្រាស់ ត្រូវបានចាត់ទុកថាបានប្រព្រឹត្តល្មើសនឹងមាត្រាទី ១៦ មាត្រាទី ១៧ មាត្រាទី ១៩ មាត្រាទី ២០ ឬ/និងមាត្រាទី ២១ ក្នុងជំពូកទី ៤ ដែលត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងមាត្រាទី ៦៣ មាត្រាទី ៦៤ ឬ/និងមាត្រាទី ៦៥ ក្នុងជំពូកទី ៧ នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា និងបណ្តាបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងទៀត។

ទទួលបានសេចក្តីណែនាំនេះ អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរណ៍ អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងអាជីវករ ពាណិជ្ជករដែលប្រកបអាជីវកម្មលោហធាតុ-ត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ និងវត្ថុអនុស្សាវរីយ៍ទាំងអស់ ត្រូវអនុវត្តទៅតាមខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែ ធ្នូ ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន-សូរស័ក្តិ**

**<u>ចម្លងជូន៖</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងទេសចរណ៍
- អង្គភាពប្រឆាំងអំពើពុករលួយ
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានកាំកុងត្រូល
- មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត
- អាជីវករ ពាណិជ្ជករ ដែលប្រកបអាជីវកម្មលោហធាតុ-ត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ និងវត្ថុអនុស្សាវរីយ៍ទាំងអស់
  "ដើម្បីចូលរួមអនុវត្ត"
- ឯកសារ-កាលប្បវត្តិ